ការផ្ទៀងផ្ទាត់ការចូលមើលតាមទូរសព្ទ (**TVV**) ត្រូវបានគេហៅផងដែរថា **IVR** គឺជាវិធីមួយ ក្នុងការកត់ត្រាពេលវេលារបស់អ្នកដែលបានធ្វើការ។ នៅពេលចាប់ផ្តើម និងចុងបញ្ចប់នៃវេនរបស់អ្នក អ្នកនឹងប្រើទូរសព្ទ ដើម្បីឱ្យប្រព័ន្ធតាមដានពេលវេលាដឹងថា អ្នកបានចាប់ផ្តើមធ្វើការ (កត់ម៉ោងចូល) និងនៅចុងបញ្ចប់នៃវេនរបស់អ្នក ដែលអ្នកបានបញ្ចប់ (កត់ម៉ោងចេញ)។ ប្រព័ន្ធប្រើប្រាស់ពាក្យ និយោជិត ដើម្បីពិពណ៌នាអំពីអ្នកថែទាំ និងពាក្យ អ្នកប្រើប្រាស់ ដើម្បីពិពណ៌នាអំពីបុគ្គលដែលទទួលសេវាកម្ម។

ចូរពិនិត្យមើលជំហានសម្រាប់ការកត់ម៉ោងចូល៖

1. ហៅទូរសព្ទទៅលេខឥតគិតថ្លៃពីទូរសព្ទ ខណ:ពេលកំពុងនៅផ្ទះរបស់អ្នកចូលរួម។
2. ចុច "1" ដើម្បីកត់ម៉ោងចូល។
3. បញ្ចូលលេខសម្គាល់និយោជិតប្រាំមួយខ្ទង់របស់អ្នក។ ប្រព័ន្ធនឹងអានលេខសម្គាល់មកអ្នកវិញ អ្នកនឹងបញ្ជាក់លេខសម្គាល់ដោយចុចលេខ "1"។
4. បញ្ចូលលេខសម្គាល់អ្នកប្រើប្រាស់ប្រាំមួយខ្ទង់។ ប្រព័ន្ធនឹងអានលេខសម្គាល់មកអ្នកវិញ អ្នកនឹងបញ្ជាក់លេខសម្គាល់ដោយចុចលេខ "1"។
5. ប្រព័ន្ធនឹងប្រកាសថា "Thank you for clocking in. Call back when you are ready to clock out. Goodbye.” (សូមអរគុណសម្រាប់ការកត់ម៉ោងចូល។ ចូរហៅមកវិញនៅពេលដែលអ្នកត្រៀមខ្លួនជាស្រេច ដើម្បីកត់ម៉ោងចេញ។ លាហើយ។")
6. ការកត់ម៉ោងចូលរបស់អ្នកបានបញ្ចប់ហើយ។

ចូរពិនិត្យមើលជំហានសម្រាប់ការកត់ម៉ោងចេញ៖

1. ហៅទូរសព្ទទៅលេខឥតគិតថ្លៃពីទូរសព្ទ ខណ:ពេលកំពុងនៅផ្ទះរបស់អ្នកចូលរួម។
2. ចុច "2" ដើម្បីកត់ម៉ោងចេញ។
3. បញ្ចូលលេខសម្គាល់និយោជិតប្រាំមួយខ្ទង់របស់អ្នក។ ប្រព័ន្ធនឹងអានលេខសម្គាល់មកអ្នកវិញ អ្នកនឹងបញ្ជាក់លេខសម្គាល់ដោយចុចលេខ "1"។
4. បញ្ចូលលេខសម្គាល់អ្នកប្រើប្រាស់ប្រាំមួយខ្ទង់។ ប្រព័ន្ធនឹងអានលេខសម្គាល់មកអ្នកវិញ អ្នកនឹងបញ្ជាក់លេខសម្គាល់ដោយចុចលេខ "1"។
5. បញ្ចូលលេខសម្គាល់កូដសេវាកម្ម។ ប្រព័ន្ធនឹងអានលេខសម្គាល់មកអ្នកវិញ អ្នកនឹងបញ្ជាក់លេខសម្គាល់ដោយចុចលេខ "1"។
6. ប្រព័ន្ធនឹងប្រកាសថា "Thank you for clocking out. Goodbye.” (សូមអរគុណសម្រាប់ការកត់ម៉ោងចេញ។ លាហើយ។)
7. ការកត់ម៉ោងចេញរបស់អ្នកបានបញ្ចប់ហើយ។

រួចរាល់ហើយ! យើងបង្កើតប្រព័ន្ធនេះឡើង ដើម្បីឱ្យមានភាពងាយស្រួលក្នុងការប្រើប្រាស់ ហើយអ្នកគួរតែចំណាយពេលតិចជាងមួយនាទីនៅពេលចាប់ផ្តើម និងពេលបញ្ចប់នៃវេននីមួយៗ ដែលអ្នកធ្វើការ។

នេះជាកន្លែងសម្រាប់អ្នកសរសេរព័ត៌មាន ដែលអ្នកនឹងត្រូវការ ពេលធ្វើការកត់ម៉ោងចូល និងម៉ោងចេញ។ អ្នកចូលរួមដែលអ្នកធ្វើការឱ្យ ឬ FMS ដែលជួយអ្នកចូលរួម នឹងផ្តល់ឱ្យអ្នកនូវព័ត៌មានដែលអ្នកត្រូវការ។

| **ព័ត៌មានដែលអ្នកត្រូវការ** | **ព័ត៌មានរបស់ខ្ញុំ** |
| --- | --- |
| លេខទូរសព្ទរបស់ TVV/IVR | |
| លេខសម្គាល់និយោជិតរបស់ខ្ញុំ | |
| លេខសម្គាល់អ្នកចូលរួម | |
| លេខសម្គាល់កូដសេវាកម្ម | |

ប្រសិនបើអ្នកនៅតែមានសំណួរ សូមទាក់ទង FMS Provider ដោយផ្ទាល់សម្រាប់ជំនួយ។



កំណែ U_1.3 © Annkissam ឆ្នាំ 2022